# កិច្ចប្រជុំគណៈកម្មាធិការជាតិសម្រាប់កិច្ចសហប្រតិបត្តិការ
# អាស៊ាន ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (NCOST)
# ស្តីពី
# ការធ្វើផែនការ និងលើកទិសដៅតាមវិស័យ សម្រាប់អនុវត្តផែនការសកម្មភាពអាស៊ាន ផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឆ្នាំ២០១៦-២០២៥ (APASTI 2016-2025)

ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី** ក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០១៦ កន្លងទៅ នៅសាលប្រជុំតូចក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានរៀបចំកិច្ចប្រជុំពិភាក្សាមួយរបស់គណៈកម្មាធិការជាតិសម្រាប់កិច្ចសហប្រតិបត្តិការអាស៊ាន ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (NCOST) ស្តីពីការធ្វើផែនការ និងលើកទិសដៅតាមវិស័យ សម្រាប់អនុវត្តផែនការសកម្មភាពអាស៊ានផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ឆ្នាំ២០១៦-២០២៥ (APASTI 2016-2025) ។

កិច្ចប្រជុំពិភាក្សាពេលនោះ ដឹកនាំដោយ **ឯកឧត្តមបណ្ឌិត ទឹង ស៊ីនី** អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងជាប្រធានគណៈកម្មាធិការជាតិ NCOST និងមានការសម្របសម្រួលពីក្រុមការងារលេខាធិការដ្ឋាន ព្រមទាំងមានការចូលរួមដោយមន្ត្រីអន្តរក្រសួង ដែលជាមន្ត្រីបង្គោលកម្ពុជានៃគណៈកម្មការអាស៊ានទាំង៩ (Sub-Committees) និងក្រុមការងារជំនាញផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា សរុបទាំងអស់ ១៦ រូប ។

កិច្ចប្រជុំបានពិនិត្យពិភាក្សាទៅលើៈ (i) ខ្លឹមសារនៃ**សកម្មភាព១៥ ចំណុច** (Actions) ទៅតាម**គោលបំណងជាយុទ្ធសាស្ត្រ** (Strategic Thrusts) **នៃផែនការសកម្មភាពអាស៊ានផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ២០១៦-២០២៥** (APASTI 2016-2025) (ii) **គោលការណ៍ណែនាំរបស់លេខាធិការដ្ឋានអាស៊ានតាមវិធាន** Logical framework ធ្វើជាមូលដ្ឋានក្នុងការវិភាគ និងលើកផែនការសកម្មភាព និងទិសដៅតាមវិស័យ និងស្របទៅតាមគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា២០១៥-២០២៥ ដើម្បីលើកស្នើឡើងតាមរយៈគណៈកម្មការអាស៊ានទាំង៩ ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (Sub-Committees) នៅខែមេសា ឆ្នាំ២០១៦ ខាងមុខនេះ ដាក់បញ្ចូលទៅក្នុងផែនការសកម្មភាពអាស៊ានសម្រាប់ APASTI 2016-2025 ដែលនឹងត្រូវពិនិត្យសម្រេចដោយគណៈកម្មាធិការអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (ASEAN COST) និង(iii) ការត្រៀមរៀបចំរបស់មន្ត្រីបង្គោលនៃគណៈកម្មការអាស៊ានទាំង៩ លើការងារវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាតាមវិស័យ សម្រាប់ដំណើរការ**កិច្ចប្រជុំលើកទី៧១របស់គណៈកម្មាធិការអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា** (COST-71) **និងកិច្ចប្រជុំក្រៅផ្លូវការលើកទី៩ របស់រដ្ឋមន្ត្រីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាស៊ាន** (IAMMST-9) ដែលនឹងប្រព្រឹត្តិទៅនៅខែតុលា ឆ្នាំ២០១៦ ខាងមុខនៅខេត្តសៀមរាប ។



